**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០១ សរ**

# សារាចរ
## ស្តីពី
## ការប្រើទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ ព្រមទាំងព្រះឆាយាល័ក្ខណ៍ព្រះអង្គទាំងបី

កន្លងមក រាជរដ្ឋាភិបាលបានសង្កេតឃើញថា នៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់បានប្រើទង់សាសនា និងទង់ព្រះមហាក្សត្រ រួមជាមួយទង់ជាតិនៅឡើយ។ ហេតុនេះ ដើម្បីលើកបង្ហាញនូវគុណតម្លៃនៃការគោរពបាវចនាជាតិ ដូចមានចែងក្នុងមាត្រា៤នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាគឺៈ ជាតិ សាសនា ព្រះមហាក្សត្រ រាជរដ្ឋាភិបាលធ្វើការណែនាំដូចខាងក្រោមៈ

១-គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ ព្រមទាំងព្រះឆាយាល័ក្ខណ៍ព្រះអង្គទាំងបី នៅក្នុងសាលប្រជុំ។

២-ទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ ព្រមទាំងព្រះឆាយាល័ក្ខណ៍ព្រះអង្គទាំងបី ត្រូវរៀបចំដូចខាងក្រោមៈ

- ទង់ជាតិត្រូវដាក់នៅកណ្តាល ទង់សាសនាត្រូវដាក់នៅខាងឆ្វេង និងទង់ព្រះមហាក្សត្រត្រូវដាក់នៅខាងស្តាំ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១។
- ការរៀបចំទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ ព្រមទាំងព្រះឆាយាល័ក្ខណ៍ព្រះអង្គទាំងបី ត្រូវអនុវត្តដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី២។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ អង្គារ ៥ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមីនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១ នៃសារាចរលេខ ...០១...សរ**

**ចុះថ្ងៃ...អង្គារ...៥...រោច... ខែ...ផល្គុន...... ឆ្នាំ រកា នព្វស័ក ព.ស.២៥៦១**

**ត្រូវនឹង ថ្ងៃទី...៦...... ខែ...មីនា......... ឆ្នាំ២០១៨**



**ឧបសម្ព័ន្ធទី២ នៃសារាចរលេខ.....០១.....សរ.....**

**ចុះថ្ងៃ.....អង្គារ.....៥.....រោច ខែ ផល្គុន.......ឆ្នាំរកា នព្វស័ក ព.ស.២៥៦១**

**ត្រូវនឹងថ្ងៃទី.........៦.........ខែ.....មីនា...........ឆ្នាំ២០១៨**

១.ទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ ត្រូវដាក់ទន្ទឹមគ្នា មានគម្លាតពីគ្នា ៥សង់ទីម៉ែត្រ គម្លាតពីពិដាន ១៥សង់ទីម៉ែត្រ និងដាក់នៅពីលើព្រះឆាយាល័ក្ខណ៍ព្រះអង្គទាំងបី ដែលមានគម្លាត ១៥សង់ទីម៉ែត្រ។

២.ទំហំទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ ព្រមទាំងព្រះឆាយាល័ក្ខណ៍ព្រះអង្គទាំងបី៖

- ទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ ត្រូវប្រើទំហំតូចបំផុតដែលមានទទឹង ០,២៥ម៉ែត្រ និងបណ្តោយ ០,៣៧៥ ម៉ែត្រ
- ព្រះឆាយាល័ក្ខណ៍ព្រះអង្គទាំងបី ត្រូវប្រើទំហំតូចបំផុតដែលមានទទឹង ០,៣០ម៉ែត្រ និង បណ្តោយ ០,៤០ម៉ែត្រ
- ទំហំទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ ព្រមទាំងព្រះឆាយាល័ក្ខណ៍ព្រះអង្គទាំងបី អាចប្រើទំហំធំជាងនេះឱ្យបានសមស្របទៅតាមទំហំនៃផ្ទៃក្រោយ (Backdrop) នៃ សាលប្រជុំដែលមានដាក់ស្តែង។